ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៩៩៤/២៦-៨-២០១៩

សាលដីកា
លេខ ២៩ ក្រIV"ណ"/០៧-៥-២១

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ភ្នំពេញ នាថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០២១ (៨"០០) ដោយមានសមាសភាពដូចខាងក្រោម ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

ឯកឧត្តម [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក ទី ចិត្តត្រា

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៩៩៤ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានជនជាប់ចោទ ៖

១/ឈ្មោះ [redacted] **ខែសា** ហៅ **សាល** ភេទប្រុស អាយុ ១៧ ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិក្រយាជើង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ទីលំនៅមុនពេលឃុំខ្លួននៅភូមិ [redacted] ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ធំ (ប្តឹងឧទ្ធរណ៍) ។

មានឈ្មោះ [redacted] សិរីរតនា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។



CS CamScanner

២/ឈ្មោះ [redacted] ផានី ភេទប្រុស អាយុ ១៨ ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិក្រយាត្បូង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ទីលំនៅមុនពេលឃុំខ្លួននៅភូមិក្រយាត្បូង [redacted] ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ធំ (ប្តឹងឧទ្ធរណ៍) ។

មានឈ្មោះ [redacted] សិរីរតនា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

<u>ជាប់ចោទពីបទ៖</u> ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅចំណុច ភូមិក្រយាត្បូង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃ ២៤ ខែ ធ្នូ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ

៣/ឈ្មោះ [redacted] ទាង ភេទប្រុស អាយុ ២០ ឆ្នាំ ជាតិខ្មែរ (មិនប្តឹងឧទ្ធរណ៍) ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លេង ភេទស្រី អាយុ ៥២ ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិ [redacted] ខេត្តកំពង់ធំ ។

<u>ឯរឿងហេតុមានដូចតទៅ</u>

**សកម្មភាព**ប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ ៖

កាលពីថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៧ វេលាម៉ោង ២០.៣០ នាទី ស្ថិតនៅចំណុចផ្លូវកែង ខាងជើងស្ពានឆ្លងស្ទឹងអន្លង់ជួរចម្ងាយប្រហែល ៨០០ ម៉ែត្រ ខាងជើងភូមិក្រយាត្បូង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ឈ្មោះ [redacted] ខៃសា ឈ្មោះ [redacted] ផានី ឈ្មោះ [redacted] ទាង និងបក្សពួកបានផឹកស៊ីស្រវឹង ហើយទៅពួនស្ទាក់ផ្លូវចាំវាយលើជនរងគ្រោះឈ្មោះ [redacted] សាយ បណ្តាលឲ្យស្លាប់បាត់បង់ជីវិតនៅកន្លែងកើតហេតុតែម្តង ។

**បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ ២៦ "ខ" ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តកំពង់ធំ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសលើជនជាប់ចោទ ៖

1/ឈ្មោះ [redacted] ខៃសា ហៅ សាល ភេទប្រុស អាយុ ១៧ ឆ្នាំ (មានសាវតាដូចខាងលើ)។

2/ឈ្មោះ [redacted] ផានី ភេទប្រុស អាយុ ១៨ ឆ្នាំ ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ។

3/ឈ្មោះ [redacted] ទាង ភេទប្រុស អាយុ ២០ ឆ្នាំ ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ។

ដាក់ពន្ធនាគារម្នាក់ៗ កំណត់រយៈពេល ១៥ (ដប់ប្រាំ) ឆ្នាំ ពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅចំណុចភូមិក្រយាត្បូង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃ ២៤ ខែ ធ្នូ ឆ្នាំ ២០១៧ តាមបញ្ញត្តិមាត្រា ២០០ និងមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

២-បង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ទាង ភេទប្រុស អាយុ ២០ ឆ្នាំ ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) យកមកអនុវត្តទោសក្នុងពន្ធនាគារខេត្តកំពង់ធំ តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

CamScanner

៣-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ខែសា ហៅ សាល ឈ្មោះ [redacted] ផានី និងឈ្មោះ [redacted] ទាង រួមគ្នាសងសំណងរដ្ឋប្បវេណីឲ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] លេម ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ។ ការទាមទារលើសពីនេះ បដិសេធចោល ។

៤-វត្ថុតាងមាន ៖

1/ដំបងឈើមូលប្រវែង ១៧០ ស.ម ទំហំ ១៧ ស.ម ចំនួន ០១
2/ដំបងឈើមូលប្រវែង ១៤៤ ស.ម ទំហំ ១១ ស.ម ចំនួន ០១
3/ដំបងឈើមូលប្រវែង ៩៦ ស.ម ទំហំ ១៥ ស.ម ចំនួន ០១
4/ដំបងឈើមូលប្រវែង ៩៨ ស.ម ទំហំ ១៧ ស.ម ចំនួន ០១
5/ស្បែកជើងផ្ទាត់ ពណ៌ ស ចំនួន ០១ គូរ
6/ស្បែកជើងផ្ទាត់កាំម្វី ពណ៌ឈាមជ្រូក ចំនួន ០១
7/ស្បែកជើងសិកស្នោ ពណ៌ខ្មៅ ចំនួន ០១ ចំហៀង

ត្រូវរឹបអូសបំផ្លាញចោល ។

៥-សាលក្រមនេះបានបញ្ចប់ការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ខែសា ហៅ សាល និងឈ្មោះ [redacted] ផានី កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ទាង និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] លេម ។

ទុកសិទ្ធិឲ្យភាគីអវត្តមានប្ដឹងទាស់ និងទុកសិទ្ធិឲ្យភាគីប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**បានឃើញ**ពាក្យបណ្ដឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ផានី និងឈ្មោះ [redacted] ខែសា ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៦ "ខ" ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តកំពង់ធំ លើចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

**បានឃើញ**របាយការណ៍រឿង ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ របស់ចៅក្រមរបាយការណ៍នៃសាលាឧទ្ធរណ៍ភ្នំពេញ ។

**បានឃើញ**សេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០២១ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ។

<u>នាពេលសវនាការ</u>

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានសង្ខេបរបាយការណ៍រឿង

-តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋានថា ផ្អែកតាមអង្គហេតុ និងការពិនិត្យសំណុំរឿងឃើញថា ជនជាប់ចោទបានឆ្លើយសារភាពដូចការចោទប្រកាន់ និងមានសាក្សីឆ្លើយបញ្ជាក់ដែរពីបទ ឃាតកម្មគិតទុកជាមុន ដែលបង្កឡើងដោយជនជាប់ចោទមានចំនួន ០៣ រូប ។ តំណាងមហាអយ្យការសុំឲ្យសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ សម្រេចតម្កល់សាលក្រមរបស់សាលាដំបូងខេត្តកំពង់ធំ ទុកជាបានការ ។

CamScanner

-ឈ្មោះ [redacted]សិរីរតនា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានសិក្សាសំណុំរឿងឃើញថា កូនក្តីខ្លួនបានឆ្លើយសារភាពទទួលស្គាល់កំហុស និងទើបប្រព្រឹត្តខុសលើកដំបូង ដោយកូនក្តីខ្លួនរៀនបានតិច ខ្វះការពិចារណា ។ កូនក្តីខ្លួនបានដឹងកំហុសដែលប្រព្រឹត្តខុសច្បាប់កន្លងទៅ ទើបប្តឹងឧទ្ធរណ៍ឡើងមកដើម្បីសុំសាលាឧទ្ធរណ៍ភ្នំពេញជួយបន្ថយសំណង និងជួយបន្ធូរបន្ថយទោសឆាប់បានចេញមកជួយរកស៊ីចិញ្ចឹមក្រុមគ្រួសារ និងសន្យាកែប្រែខ្លួនជាពលរដ្ឋល្អក្នុងសង្គមជាតិវិញ ។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

<u>សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញយល់ឃើញថា</u>

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ជានី និងឈ្មោះ [redacted] ខែសា ប្តឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌលេខ ២៦ "ខ" ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តកំពង់ធំ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល បានធ្វើឡើងត្រឹមត្រូវតាមច្បាប់ យោងតាមមាត្រា ៣៧៣ មាត្រា ៣៧៥ មាត្រា ៣៧៦ និងមាត្រា ៣៨២ ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអាចឲ្យសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ទទួលបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទទាំងពីររូប មកធ្វើការជំនុំជម្រះជាសមត្ថកិច្ច ។

២-នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ជានី និងឈ្មោះ [redacted] ខែសា អវត្តមាន ។

ជនជាប់ចោទទាំងពីររូប នៅដំណាក់កាលសាលាដំបូងខេត្តកំពង់ធំ ឆ្លើយសារភាពថា ពួកខ្លួនពិតជាបានពួនស្ទាក់ចាំវាយជនរងគ្រោះ និងបានវាយជនរងគ្រោះ បណ្តាលឲ្យស្លាប់ប្រាកដមែន ។ អំពើប្រព្រឹត្តរបស់ជនជាប់ចោទទាំងពីររូប គឺជាបទល្មើស ឃាតកម្មគិតទុកជាមុន បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ។

៣-ផ្អែកតាមសំអាងហេតុខាងលើ ឃើញថា សំអាងហេតុ និងសេចក្តីសម្រេចក្នុងសាលក្រមព្រហ្មទណ្ឌលេខ ២៦ "ខ" ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តកំពង់ធំមានមូលហេតុត្រឹមត្រូវ គប្បីសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ សម្រេចបដិសេធពាក្យបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ ចោលជាអសារបង់ ព្រោះថា ទោសពន្ធនាគាររយៈពេល ១៥ (ដប់ប្រាំ) ឆ្នាំ ដែលសាលាដំបូងខេត្តកំពង់ធំ បានប្រកាសលើជនជាប់ចោទទាំងពីររូប និងបង្គាប់ឲ្យជនជាប់ចោទទាំងពីររូប រួមគ្នាសងសំណងចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី គឺមានលក្ខណៈស្រាល បើប្រៀបធៀបនឹងទោសដែលត្រូវប្រកាសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ហើយសំណងចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ក៏មិនធន់ល្មមនឹងការបាត់បង់អាយុជីវិតរបស់ជនរងគ្រោះ និងព្យសនកម្មដែលកើតមានចំពោះដើមបណ្តឹង

CamScanner

រដ្ឋប្បវេណី ដូច្នេះ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ មិនអាចបន្ថយទោស និងសំណងជូនជនជាប់ចោទទាំងពីររូបបានទេ ។

៤-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទទាំងពីររូបឆ្លើយសារភាពដូចការចោទប្រកាន់ ដូច្នេះ សុំក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមរបស់សាលាដំបូងខេត្តកំពង់ធំទុកជាបានការ ។ ការស្នើសុំនេះ មានមូលហេតុត្រឹមត្រូវ ផ្អែកតាមសំអាងហេតុខាងលើ ។

៥-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនបានឆ្លើយសារភាពដឹងកំហុស និងសំដែងភាពស្មោះត្រង់ ។ កូនក្តីខ្លួនមានចំណេះដឹងទាប និងទើបប្រព្រឹត្តបទល្មើសជាលើកដំបូង ដូច្នេះ សុំឲ្យក្រុមប្រឹក្សាជួយបន្ធូរបន្ថយទោស និងសំណងឲ្យបានទាបបំផុត ។

ការស្នើសុំនេះ ពុំមានមូលហេតុត្រឹមត្រូវ ផ្អែកតាមសំអាងហេតុខាងលើ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-បដិសេធពាក្យបណ្តឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ជានី និងឈ្មោះ [redacted] ខែសា ចោលជាអសារបង់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៦ "ខ" ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តកំពង់ធំ ទុកជាបានការ ។

៣-បន្តការឃុំខ្លួនជនជាប់ចោទទាំងពីររូបតាមច្បាប់ ។

៤-សាលដីកានេះជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០២១ កំបាំងមុខជនជាប់ចោទទាំងពីររូប និងប្រកាសជាសាធារណៈ នៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០២១ កំបាំងមុខជនជាប់ចោទទាំងពីររូប ទុកសិទ្ធិឲ្យប្តឹងទាស់ និងប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] [redacted] | ហត្ថលេខា [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី 01 ខែ 6 ឆ្នាំ ២០២១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

CamScanner